00654981

E65/1/1

# ក្រុមមេធាវីការពារក្តី អៀង សារី
# IENG SARY DEFENCE TEAM
# EQUIPE DE DEFENSE DE IENG SARY

សាធារណៈ / Public

---

**អាង ឧត្តម និង Michael G. KARNAVAS**

**សហមេធាវីការពារក្តី អៀង សារី**

ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១១

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 17 / 03 / 2011
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

គោរពជូន: **ចៅក្រម និល ណុន**

**ចៅក្រម យូ មណី**

**ចៅក្រម យ៉ា សុខន**

**ចៅក្រម Silvia CARTWRIGHT**

**ចៅក្រម Jean-Mare LAVERGNE**

**ចៅក្រម យូរ ឧត្តរា**

**ចៅក្រម Claudia FENZ**

ចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូង

**អ្នកស្រី Susan Lamb**

មន្ត្រីច្បាប់ជាន់ខ្ពស់នៅអង្គជំនុំជម្រះសាលាដំបូង

**លោក Matteo CRIPPA**

**លោក លឹម ស៊ុយហុង**

ក្រឡាបញ្ជីនៅអង្គជំនុំជម្រះសាលាដំបូង

ចម្លងជូន: **លោក គាំ ចាន់មុន្នី**

ប្រធានអង្គភាពបកប្រែឯកសារ និងបកប្រែផ្ទាល់មាត់

**អ្នកស្រី Nisha Valabhji**

អនុប្រធាន និងប្រធានស្តីទីអង្គភាពគាំពារការការពារក្តី

**ឯកឧត្តម ក្រាញ់ តូនី**

ប្រធានស្តីទីការិយាល័យរដ្ឋបាល

**លោក Knut ROSANDHAUG**

អនុប្រធានការិយាល័យរដ្ឋបាល

---

00654982

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ការិយាល័យសហព្រះរាជអាជ្ញា**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

កម្មវត្ថុ: អនុស្សរណៈរបស់លោក/លោកស្រីចៅក្រមបង្គាប់អង្គភាពបកប្រែឯកសារ និង បកប្រែផ្ទាល់មាត់ ឱ្យបញ្ឈប់ការបកប្រែឯកសារជាក់លាក់របស់យើងខ្ញុំ

លោក/លោកស្រីចៅក្រម មន្ត្រីច្បាប់ និងក្រឡាបញ្ជីជាទីរាប់អាន

យើងខ្ញុំសរសេរជម្រាបជូនលោក/លោកស្រីចៅក្រម ទាក់ទងនឹងការអនុវត្តការបង្គាប់របស់លោក/លោកស្រីចៅក្រមទៅអង្គភាពបកប្រែឯកសារ និងបកប្រែផ្ទាល់មាត់ ("អង្គភាពITU") ឱ្យបញ្ឈប់ការបកប្រែឯកសារជាក់លាក់មួយចំនួនរបស់យើងខ្ញុំ ។ លោក/លោកស្រីចៅក្រមបានបង្គាប់ឱ្យអង្គភាព ITU បញ្ឈប់ការបកប្រែឯកសាររបស់យើងខ្ញុំចំនួនបីឱកាសរួចមកហើយ[1] ។ នៅក្នុងឱកាសពីរលើកចុងក្រោយជាប់ៗនេះ លោក/លោកស្រីចៅក្រមបានគូសបញ្ជាក់ថា អង្គភាព ITU ត្រូវបានបង្គាប់ឱ្យបញ្ឈប់ការបកប្រែ ពីព្រោះញត្តិនេះពុំមានមូលដ្ឋានច្បាប់"[2] ។ លោក/លោកស្រីចៅក្រមបានស្នើឱ្យអង្គភាពគាំពារការការពារក្តី ("អង្គភាពDSS") ពិនិត្យការដាក់ឯកសារជាក់លាក់របស់យើងខ្ញុំ ស្របតាមអំណាច

[1] សូមមើល*ករណី នួន ជា* ០០២/១៩-០៩-២០០៧-អវតក/អជសដ ការជូនដំណឹងរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងនីតិវិធីដែលត្រូវបានកែប្រែសម្រាប់ដាក់អញ្ញត្រកម្ម និងការបញ្ជាក់ពីកាលបរិច្ឆេទសម្រាប់ការឆ្លើយតប ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ ERN: 00644105-00644106 នៅទំព័រទី២ ។ *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក/អជសដ អនុស្សរណៈជាការឆ្លើយតបទៅនឹងសំណើដែលដាក់ដោយ អៀង សារី (53/2) ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១១ E53/2/1, ERN: 00651551-00651551 ។ *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក/អជសដ អនុស្សរណៈស្តីពីសំណើរបស់ អៀង សារី សុំដាក់ញត្តិស្វែងរក "ការបញ្ជាក់ថាគាត់ត្រូវមានសិទ្ធិបង្ហាញអំណះអំណាងផ្ទាល់មាត់នៅសវនាការបឋម ទាក់ទងនឹងអញ្ញត្រកម្មនីមួយៗរបស់គាត់" ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ ២០១១ E65/1, ERN: 00651599-00651600 ។

[2] សូមមើល*ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក/អជសដ អនុស្សរណៈជាការឆ្លើយតបទៅនឹងសំណើដែលដាក់ដោយ អៀង សារី (53/2) ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១១ E53/2/1, ERN: 00651551-00651551 ។ *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក/អជសដ អនុស្សរណៈស្តីពីសំណើរបស់ អៀង សារី សុំដាក់ ញត្តិស្វែងរក "ការបញ្ជាក់ថាគាត់ត្រូវមានសិទ្ធិបង្ហាញអំណះអំណាងផ្ទាល់មាត់នៅសវនាការបឋម ទាក់ទងនឹងអញ្ញត្រកម្មនីមួយៗរបស់គាត់" ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ ២០១១ E65/1, ERN: 00651599-00651600 ។

របស់អង្គភាព DSS ក្នុងការបដិសេធមិនបង់ប្រាក់កំរៃសម្រាប់ការដាក់ឯកសារទាំងឡាយណា ដែលមិន "ចាំបាច់ និងមិនសម-ហេតុផល" ។ ការអនុវត្តបែបនេះបង្កឲ្យមានការព្រួយបារម្ភណ៍ និងចោទជាបញ្ហាមួយចំនួន ។

ជាបឋម ដោយការគោរពយើងខ្ញុំសូមសួរថា តើលោក/លោកស្រីចៅក្រមមានអំណាចអ្វីខ្លះដើម្បីបង្គាប់ឲ្យអង្គភាព ITU ត្រូវបកប្រែឯកសារមួយណា ហើយឯកសារមួយណាមិនត្រូវបកប្រែនោះ ។ អង្គភាព ITU ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ផ្នែកគ្រប់គ្រងតុលាការ មិនមែនអង្គជំនុំជម្រះសាលាដំបូងនោះទេ ។ ប្រសិនបើលោក/លោកស្រីចៅក្រម មានអំណាចគ្មានព្រំដែនកំណត់ដើម្បីបង្គាប់សកម្មភាពរបស់អង្គភាព ITU នោះនៅក្នុងករណីសេណារីយ៉ូដ៏អាក្រក់មួយ ការធ្វើដូច្នេះអាចបង្កើតបញ្ហាយ៉ាងធ្ងន់ធ្ងរនៅក្នុងតុលាការនេះ។ ឧទាហរណ៍ លោក/លោកស្រីចៅក្រមអាចរាំងខ្ទប់ការបកប្រែសំណើសុំប្តឹងជំទាស់ប្រឆាំងចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ឬ អាចមានបំណងមិនចង់អោយគេដាក់នូវបណ្តឹងសាទុក្ខជាក់លាក់មួយចំនួនដូច្នេះហើយអាចរាំងខ្ទប់ការដាក់បណ្តឹងសាទុក្ខមួយចំនួនបាន ។ ទាំងនេះគឺជាករណីជ្រៀតជ្រែកក្នុងរដ្ឋបាលតុលាការយ៉ាងពិតប្រាកដ ។ សំនួរសួរថា តើគេអាចកំណត់ថាឯកសារយ៉ាងដូចម្តេចដែលអាចធ្វើអោយលោក/លោកស្រីចៅក្រមយល់ថាត្រូវរាំងខ្ទប់មិនឲ្យបកប្រែ និងប្រភេទណាដែលមិនត្រូវអនុវត្តការរាំងខ្ទប់ក្នុងការបកប្រែនេះ ។ រឿងនេះប្រហែលវាជាបញ្ហាមួយផ្សេងទៀតដែលត្រូវលើកយកមកពិភាក្សានៅក្នុងកិច្ចប្រជុំរៀបចំសវនាការ ដើម្បីបញ្ចៀសការយល់ឃើញច្រលំនាពេលអនាគត ឬ សកម្មភាពនានាដែលអាចបង្កឲ្យមានការប៉ះពាល់ធ្ងន់ធ្ងរដល់ការរៀបចំការការពារលោក អៀង សារី ទាំងមូល។

ទីពីរ យើងខ្ញុំព្រួយបារម្ភរណ៍ថា លោក/លោកស្រីចៅក្រមបានសម្រេចថាឯកសារមួយណាដែលលោក/លោកស្រីចៅក្រមជឿជាក់ថាមានមូលដ្ឋានផ្នែកច្បាប់ <u>សូម្បីតែនៅមុនពេល</u>ឯកសារទាំងនេះត្រូវបានបកប្រែជាភាសាសម្រាប់ សមាជិកភាគច្រើននៃអង្គចៅក្រម ។ សំនួរសួរថា តើចៅក្រមកម្ពុជាអាចយល់ពីអត្ថន័យលំអិត និងអង្គសេចក្តីរបស់សារណាយ៉ាងដូចម្តេច បើចៅក្រមទាំងនេះមិនអាចអានខ្លឹមសារពិតប្រាកដរបស់សារណានេះផងនោះ? តើចៅក្រមទាំងនេះអាចសម្រេចយ៉ាងដូចម្តេចបានថា ឯកសារនេះគឺ "ចាំបាច់ និងសមហេតុផលនោះ"?[3]

---

[3] នៅក្នុងអនុស្សរណៈថ្មីបំផុតរបស់លោក/លោកស្រីចៅក្រម លោក/លោកស្រីចៅក្រមស្នើអង្គភាព DSS ពិនិត្យថាតើការដាក់ឯកសារជាក់លាក់ គឺ "ចាំបាច់ និងសមហេតុផល" ។ សូមមើល*ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក/អជសដ អនុស្សរណៈ ជាការឆ្លើយតបទៅនឹងសំណើដែលដាក់ដោយ អៀង សារី (53/2) ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១១ E53/2/1, ERN: 00651551-00651551 ។ *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក/អជសដ អនុស្សរណៈស្តីពីសំណើរបស់ អៀង

ទីបី យើងខ្ញុំមិនដែលទទួលបានការណែនាំពិតប្រាកដដែល លោក/លោកស្រីចៅក្រមផ្តល់ឱ្យអង្គភាព ITU នៅពេលលោក/លោកស្រីចៅក្រមបង្គាប់អង្គភាពនេះមិនឱ្យបកប្រែឯកសារ ។ អាស្រ័យហេតុនេះ យើងខ្ញុំមិនប្រាកដប្រជាថា តើការបង្គាប់ទាំងនេះមានខ្លឹមសារជាក់លាក់យ៉ាងដូចម្តេចទេ ។ យើងខ្ញុំព្រួយបារម្ភណ៍ថា លោក/លោកស្រីចៅក្រមប្រហែលជាមិនមានចេតនាធ្វើឱ្យច្របូកច្របល់នៅក្នុងអង្គភាព ITU ដោយសារការចេញសេចក្តីបង្គាប់មិនច្បាស់លាស់បែបនេះទេ ។ ឧទាហរណ៍ នាពេលថ្មីៗនេះ លោក/លោកស្រីចៅក្រមបានបង្គាប់ឱ្យអង្គភាព ITU បញ្ឈប់ការបកប្រែសំណើរបស់ អៀង សារី សុំឱ្យមានការបញ្ជាក់ថា គាត់ត្រូវតែមានសិទ្ធិបង្ហាញអំណះអំណាងផ្ទាល់មាត់នៅសវនាការបឋម ទាក់ទងនឹងអញ្ញត្រកម្មនីមួយៗរបស់គាត់ ។ ប្រសិនបើ/លោកស្រីចៅក្រមគ្រាន់តែបង្គាប់អង្គភាព ITU ឱ្យបញ្ឈប់ការបកប្រែ "ការដាក់ឯកសារអញ្ញត្រកម្ម" ឬ អ្វីមួយដែលស្រដៀងគ្នា នោះអង្គភាព ITU អាចបញ្ឈប់ដោយភាន់ច្រឡំនូវការបកប្រែបណ្តឹងឧទ្ធរណ៍មួយដែលយើងខ្ញុំកំពុងដាក់អោយបកប្រែ ដែលទាក់ទងនឹងបញ្ហាអញ្ញត្រកម្ម ។ វាអាចធ្វើឱ្យយើងខ្ញុំខកខានដាក់ឯកសារតាមកាលបរិច្ឆេទកំណត់ ។ គេត្រូវយកចិត្តទុកដាក់ខ្ពស់បំផុតក្នុងការចេញសេចក្តីបង្គាប់ទាំងនេះ ដើម្បីធានាថាសេចក្តីបង្គាប់ទាំងនេះមិនបណ្តាលឱ្យមានភាន់ច្រឡំ ឬ ការអាក់ខានដល់ការបកប្រែ ដែលលោក/លោកស្រីចៅក្រមមិនមានបំណងរំខានឡើយ ។

ទីបួន ការអនុវត្តការរាំងខ្ទប់អង្គភាព ITU មិនឱ្យបកប្រែឯកសាររបស់យើងខ្ញុំ បានទប់ស្កាត់ពួកយើងមិនឱ្យបង្កើតកំណត់ត្រាដែលភាគី<u>ទាំងអស់</u>អាចពិនិត្យមើល ។ នៅក្នុងឧទាហរណ៍ថ្មីបំផុត លោក/លោកស្រីចៅក្រមបាន អនុញ្ញាតឱ្យអត្ថបទជាភាសាអង់គ្លេសនៃឯកសាររបស់យើងខ្ញុំដាក់ទៅក្នុងសំណុំរឿង តែបានរាំងខ្ទប់អង្គភាព ITU មិនឱ្យបកប្រែឯកសារទាំងនេះទៅជាភាសាខ្មែរ ដែលការណ៍នេះរារាំងជនទាំងឡាយណាដែលប្រើប្រាស់ភាសាខ្មែរជាជាងភាសាអង់គ្លេស មិនអាចពិនិត្យមើលឯកសារទាំងនេះបានទេ ។

ជាចុងក្រោយ យើងខ្ញុំសូមស្នើដោយគោរពសុំលោក/លោកស្រីចៅក្រមផ្តល់លក្ខណៈវិនិច្ឆ័យ ដែលអាចត្រូវបានប្រើប្រាស់សម្រាប់ការកំណត់ថា តើឯកសារអាចត្រូវបានពិចារណាថា "ចាំបាច់ និងសមហេតុផល" ។ យើងខ្ញុំ ស្នើសុំឱ្យពិចារណាថា ក្នុងនាមជាមេធាវីការពារក្តីដែលចាត់តាំងដោយលោក អៀង សារី ដែលតែងតែពិគ្រោះយោបល់ជាទៀងទាត់ជាមួយកូនក្តី និងបានចូលរួមក្នុងដំណើរការនីតិវិធីតាំងពីគ្រាដំបូង <u>យើងខ្ញុំ</u> ស្ថិតនៅក្នុងស្ថានភាពដ៏ប្រសើរមួយ ដែលអាចកំណត់ថា ការដាក់ឯកសារណាមួយដែលចាំបាច់ និង

សារី សុំដាក់ញត្តិស្វែងរក "ការបញ្ជាក់ថាគាត់ត្រូវមានសិទ្ធិបង្ហាញអំណះអំណាងផ្ទាល់មាត់នៅសវនាការបឋម ទាក់ទងនឹងអញ្ញត្រកម្មនីមួយៗរបស់គាត់" ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ ២០១១ E65/1, ERN: 00651599-00651600 ។

សមហេតុផលសម្រាប់កិច្ចការការពារក្តីរបស់គាត់ ។ យើងខ្ញុំត្រូវតែប្រកាន់ភ្ជាប់នូវកាតព្វកិច្ចក្រមសីលធម៌ដើម្បីការពារលោក អៀង សារី ប្រកបដោយវីរិយៈភាព និងឲ្យអស់ពីសមត្ថភាពរបស់យើងខ្ញុំ ។ យើងខ្ញុំមិនអាចដាក់កំហិតការដាក់ឯកសាររបស់យើងខ្ញុំ ដោយផ្អែកលើការពិចារណាដែលមិនសមរម្យ ដូចជាថាតើឯកសារទាំងនេះត្រូវការធនធានខាងបកប្រែចំនួនប៉ុន្មាននោះទេ ។

យើងខ្ញុំសូមស្នើដោយគោរពថា លោក/លោកស្រីចៅក្រមមេត្តាពិចារណាចំពោះការព្រួយបារម្ភរណ៍ខាងលើ និងបញ្ឈប់ការបង្គាប់អង្គភាព ITU ថាតើត្រូវបកប្រែឬមិនត្រូវបកប្រែឯកសារ ។ បើសិនលោក/លោកស្រីចៅក្រមសម្រេចបន្តការអនុវត្តបែបនេះ យើងខ្ញុំសូមស្នើដោយគោរពដល់លោក/លោកស្រីចៅក្រមមេត្តាប្រាប់ដល់យើងខ្ញុំថា លោក/លោកស្រីចៅក្រមមានអំណាចអ្វីខ្លះក្នុងការបង្គាប់អង្គភាព ITU និងថាតើលោក/លោកស្រីចៅក្រមសម្រេចថា កាលៈទេសៈណាមួយដែលអាចទទួលយកបានក្នុងការអនុវត្តអំណាចនេះ។ យើងខ្ញុំក៏ស្នើសុំបន្ថែមទៀតអោយមានការបញ្ជាក់ថា តើការដាក់ឯកសារដែល "ចាំបាច់ និងសមហេតុផល" នោះមានន័យយ៉ាងដូចម្តេច ។

សូមលោក/លោកស្រីទាំងអស់ទទួលនូវការរាប់អានដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ។

AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្តម** | **Michael G. KARNAVAS**

**សហមេធាវីការពារក្តី អៀង សារី**